# ៧. បញ្ហាសំខាន់ៗនៅក៏រិតមីក្រូ

នៅពេលដែលសិទ្ធិមនុស្សត្រូវបានប្រកាសជាសកល បញ្ហាជាច្រើនបានកើតឡើងទាក់ទងនឹងការគោរពសិទ្ធិមនុស្ស។ ប្រហាក់ប្រហែលគ្នានេះដែរ បញ្ហាដូចគ្នាត្រូវបានជួបប្រទះក្នុងប្រទេសជាច្រើន ហើយប្រទេសនីមួយៗអាចទាញយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហានេះ។ ដូច្នេះ នៅពេលដែលប្រទេសមួយត្រូវប្រមូលទិន្នន័យច្រើនប្រភេទសំរាប់ចងក្រងជាឯកសារទាក់ទងនឹងឧបសគ្គនានា ការអប់រំដែលផ្អែកលើសិទ្ធិផ្តល់ការណែនាំជារួមនៃបទពិសោធន៍ទាំងឡាយសំរាប់កត់សំគាល់ និងដោះស្រាយបញ្ហាក្នុងក្របខ័ណ្ឌសកល។

**ហេដ្ឋារចនាសម្ព័ន្ធ**

ច្បាប់សិទ្ធិមនុស្សបានណែនាំការផ្តួចផ្តើមនីតិវិធីថ្មី ២ : ទីមួយ បញ្ជាក់ថា ជនគ្រប់រូប រួមទាំងកុមារមានសិទ្ធិស្មើគ្នា។ ទីពីរ ឯកសារពាក់ព័ន្ធនានាត្រូវបង្កើតឡើងឲ្យមានជាយន្តការចាំបាច់ដើម្បីបង្ហាញអំពីសិទ្ធិទាំងនោះ និងធានាថាសិទ្ធិទាំងនោះត្រូវបានគេគោរព និងអនុវត្តនៅគ្រប់ថ្នាក់ទាំងអស់ក្នុងសង្គម។ ការអប់រំដោយផ្អែកលើសិទ្ធិអាស្រ័យលើភាពស៊ីចង្វាក់គ្នានៃស្ថាប័ន និងច្បាប់នានា។ កាតព្វកិច្ចនៃការគោរពសិទ្ធិមនុស្សត្រូវធ្វើនៅគ្រប់ផ្នែកទាំងអស់របស់រដ្ឋាភិបាល ដោយមិនគិតពីការបែងចែកអំណាច និងទំនួលខុសត្រូវ និងទាមទារឲ្យមានការបង្កើតក្របខ័ណ្ឌគតិយុទ្ធពិស្តារ និងឯកភាពគ្នាមួយសំរាប់ការអប់រំដែលបានគិតគូរដល់គោលដៅនៃការអប់រំសំរាប់ទាំងអស់គ្នា និងតួនាទីផ្សេងៗរបស់ស្ថាប័នរដ្ឋាភិបាល។ កាតព្វកិច្ចនេះគ្របដណ្តប់លើផ្នែកដ៏ធំរបស់ស្ថាប័នរដ្ឋ និងឯកជន។ ឧទាហរណ៍ នៅប្រទេស សិង្ហបុរី ក្រសួង និងភ្នាក់ងារ ១៣ រួមបញ្ចូលគ្នាបង្កើតគណៈកម្មការអន្តរក្រសួងទទួលបន្ទុកលើការលុបបំបាត់ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រី។[៧២]

បើយកចិត្តទុកដាក់លើការធានាផ្តល់សិទ្ធិមនុស្សខ្លាំងពេកដោយមិនបានគិតគូរអំពីការបង្កើតនីតិវិធីដែលមានប្រសិទ្ធភាពសំរាប់ដោះស្រាយបញ្ហាគឺជាការឥតប្រយោជន៍។ ភាពច្បាស់លាស់នៅក្នុងសិទ្ធិបុគ្គលគឺត្រូវមានសិទ្ធិទទួលដំណើរការ និងមធ្យោបាយដូចគ្នាក្នុងការកាត់ក្តីឲ្យស្មើភាពគ្នាអំពីការប្តឹងផ្តល់ណាមួយ។ ដោយហេតុនេះ ទន្ទឹមនឹងការវិវត្តន៍នៃច្បាប់សិទ្ធិមនុស្ស ត្រូវបង្កើតហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នវិសាមញ្ញ និងពេញសមត្ថភាពសំរាប់ដោះស្រាយរាល់ការរំលោភសិទ្ធិមនុស្ស ដោយធ្វើការជាមួយតុលាការ និងស្នងការសិទ្ធិមនុស្សនៅជុំវិញពិភពលោក។

ផ្ទុយនឹងទស្សនៈយល់ឃើញញឹកញាប់នៃការគោរពសិទ្ធិមនុស្សដែលមានតែទៅលើជនស៊ីវិល និងអ្នកនយោបាយស្នងការសិទ្ធិមនុស្សហាក់ដូចជាមានបន្ទុកច្រើនដែលសុទ្ធតែជាការប្តឹងផ្តល់ប្រឆាំងនឹងការរំលោភច្បាប់សេដ្ឋកិច្ច និងសិទ្ធិសង្គមកិច្ច។ ឧទាហរណ៍ ប្រហែល ៤៤,៥ ភាគរយនៃករណីទាំងអស់ ដែលដោះស្រាយដោយស្នងការជាតិឥណ្ឌូណេស៊ីទទួលបន្ទុកសិទ្ធិមនុស្សនៅឆ្នាំ ២០០២ ទាក់ទងនឹងការរំលោភបំពានសិទ្ធិសុខុមាលភាពសាធារណៈ។[៧៣]

តារាងទី ១៨ បង្ហាញពីរបៀបដែលការអប់រំដោយផ្អែកលើសិទ្ធិមនុស្សអាចអនុវត្តបាន។ តារាងបង្ហាញពីបញ្ហាថ្មីៗដែលកើតមាន និងការណែនាំសំរាប់ទិន្នន័យគុណវិស័យ និងបរិវិស័យដែលត្រូវប្រមូលពីព័ត៌មានស្ថិតិដែលមានស្រាប់ ឬជួនកាលត្រូវប្រមូលថ្មី។

---

72 Second periodic report of Singapore, U.N. Doc. CEDAW/C/SGP/2, 2001, para 2.1.

73 The National Commission on Human Rights Indonesia - Annual Report 2000 , Jakarta, 2001, p. 69.

**តារាងទី ១៨ : ការអនុវត្តល្អៗទាក់ទងនឹងការត្រួតពិនិត្យ តាមដានការអប់រំយកសិទ្ធិជាមូលដ្ឋាន**

| | បញ្ហាគន្លឹះ | បទពិសោធន៍អនុវត្តល្អៗ |
|---|---|---|
| **ធនធានរូបវ័ន្ត** | (១) ការឆ្លើយតបគ្នារវាងការបែងចែកថវិកា និងកាតព្វកិច្ចសិទ្ធិមនុស្ស | (១) ការបែងចែកថវិកាផ្អែកលើតម្លៃប៉ាន់ប្រមាណគុណភាពអប់រំសំរាប់រាល់កាតព្វកិច្ចបំពេញបន្ថែម ដោយការបំពេញបន្ថែមឬកែតម្រូវសិទ្ធិមនុស្សចំពោះអ្វីដែលមិនធ្វើតាម។ |
| | (២) ការព្រមព្រៀងគ្នារវាងការផ្តល់ការអប់រំ (សាលាចំនេះទូទៅ សាលាឯកជន និងអប់រំក្រៅប្រព័ន្ធ) និងកុមារគ្រប់អាយុចូលរៀន | (២) កំណត់សំគាល់គម្លាតក្នុងការផ្តល់ការអប់រំ និងវិធានការដើម្បីបំបាត់គម្លាតនេះ |
| | (៣) មុខរបរបង្រៀន | (៣) ពិនិត្យសិទ្ធិមនុស្ស និងស្តង់ដាច្បាប់ពលកម្មសំរាប់គ្រូ |
| **ឱកាសចូលរៀន** | (៤) ពិនិត្យរកមើលកុមារដែលមិនបានចូលរៀនឲ្យបានញឹកញាប់ និងកត់សំគាល់ពីហេតុផលនៃការមិនបានចូលរៀនរបស់ពួកគេ | (៤) វិធានការធានាឲ្យមានការចូលរៀនរបស់កុមារដែលគេទាត់ចោលពីមុន ឬត្រូវផ្តល់ការអប់រំនៅកន្លែងដែលមាន កុមាររស់នៅ |
| | (៥) កត់សំគាល់ឧបសគ្គទាំងឡាយដែលរារាំងកុមារមិនឲ្យរៀនចប់កំរិតអប់រំដោយកាតព្វកិច្ចដោយកុមារទាំងអស់ | (៥) យុទ្ធសាស្រ្តពិស្តារសំរាប់លុបបំបាត់រាល់ឧបសគ្គទាំងឡាយ (ច្បាប់ រដ្ឋបាល ហិរញ្ញវត្ថុ ...) |
| **កែប្រែការអប់រំឲ្យស្របតាមតម្រូវការជាក់ស្តែង** | (៦) ស្តង់ដាគុណភាព | (៦) ត្រួតពិនិត្យស្ថាប័នអប់រំទាំងអស់ដើម្បីធានានូវការអនុលោមតាមស្តង់ដាគុណភាព |
| | (៧) ការបង្រៀនដោយផ្អែកលើសិទ្ធិ | (៧) សុវត្ថិភាពសិទ្ធិមនុស្ស សំរាប់ខ្លឹមសារកម្មវិធីអប់រំ និងសៀវភៅសិក្សា វិធីសាស្រ្តបង្រៀន និងវិន័យ |
| | (៨) លុបបំបាត់ឧបសគ្គទាំងអស់នៅក្នុងការសិក្សា | (៨) សម្របសម្រួលទៅតាមភាសា សាសនា ពិការភាព បរិយាកាសគ្រួសារ សុខភាព និងឋានៈ |
| **ភាពអាចទទួលយកបាន** | (៩) ការព្រមព្រៀងគ្នានៃអាយុ | (៩) យុទ្ធសាស្រ្តសិទ្ធិកុមារនៅគ្រប់អាយុទាំងអស់ (ការអប់រំ ការងារ ការរៀបការ ...) |
| | (១០) កំណត់ការអប់រំឲ្យត្រឹមត្រូវដើម្បីពង្រឹងសិទ្ធិមនុស្ស | (១០) ការវាយតម្លៃផលប៉ះពាល់សិទ្ធិ មនុស្ស (ការអត់ការងារធ្វើរបស់អ្នករៀនចប់ ការបែងចែកសេដ្ឋកិច្ច សង្គម សមភាពយេនឌ័រ ការការពារមិនឲ្យមានជម្លោះ។ |